ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភា
# ប្រចាំខែសីហា ឆ្នាំ២០១៩

*នៅក្នុងខែសីហា ឆ្នាំ២០១៩នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅ៖*

**១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា**

**១.១-សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បាន :**

*-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៤ ចំនួន ០១លើក និងកិច្ចប្រជុំព្រឹទ្ធសភាជាវិសាមញ្ញចំនួន០១លើក*

*-អញ្ជើញថ្វាយព្រះរាជដំណើរ* ***ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី*** *ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ស្តេចយាងទៅពិនិត្យ និងព្យាបាលព្រះរាជសុខភាព នៅទីក្រុងប៉េកាំង នៃសាធារណរដ្ឋប្រជាមានិតចិន*

*-អនុញ្ញាតឱ្យឯកឧត្តម* Hidehisa HORINOUCHI *ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពនៃព្រះរាជាណាចក្រជប៉ុនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងជម្រាបលា*

*-អនុញ្ញាតឱ្យឯកឧត្តម* NGUYEN VANNEN *លេខាធិការមជ្ឈិមបក្ស និងជាប្រធានខុទ្ទកាល័យមជ្ឈិមបក្សកុម្មុយនីស្តវៀតណាមនៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងគណៈប្រតិភូ ចូលជួបសម្តែងការគួរសម*

*-អញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីលៀងសាយភោជន៍ ជូនជាកិត្តិយសចំពោះឯកឧត្តម* ***ម៉ៃទ្រីប៉ាឡា ស៊ីរីសេនា*** *ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាធិបតេយ្យសង្គម-និយមស្រីលង្កា និង* ***លោកជំទាវ*** *ព្រមទាំងគណៈប្រតិភូ នៅព្រះរាជដំណាក់សិរីមង្គលក្នុងព្រះបរមរាជវាំង*

*-អញ្ជើញជួបសំណេះសំណាលជាមួយក្រុមនិស្សិតចំនួន២៤រូប ដែលជាបេក្ខជនបេក្ខនារីជ័យលាភីអាហារូបករណ៍ទៅសិក្សានៅព្រះរាជាណាចក្រជប៉ុនសម្រាប់ឆ្នាំ២០១៩-២០២១ និងអ្នកតន្ត្រីករ គ្រូតូរ្យតន្ត្រី សិល្បករ សិល្បការិនី ចំនួន៤០រូប ដែលមានអាជីពជំនាញតូរ្យតន្ត្រី*

-អញ្ជើញជួបសំណេះសំណាល និងសាកសួរសុខទុក្ខ បងប្អូនប្រជាពលរដ្ឋ កងកម្លាំង នៅភូមិព្រៃកតាពៅ សង្កាត់ព្រៃកប្រា ខណ្ឌច្បារអំពៅ ភូមិដើមគរ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ សង្កាត់ពន្សាំង ខណ្ឌព្រែកព្នៅ និងបានពិសារអាហារថ្ងៃត្រង់ជាមួយ កងកម្លាំងនគរបាលប៉ុស្តិ៍រដ្ឋបាលសង្កាត់ ប្រជាការពារភូមិ នៅសង្កាត់ស្នោ ខណ្ឌកំបូល រាជធានីភ្នំពេញ

-អញ្ជើញជួបសំណេះសំណាលជាមួយកម្មករ និយោជិត រោងចក្រ សហគ្រាស និងគ្រឹះស្ថាន ដែលមានមូលដ្ឋានក្នុងភូមិសាស្ត្រ ខណ្ឌចំនួន៨ ក្នុងរាជធានីភ្នំពេញ មាន ចំនួនប្រមាណ៣២០០នាក់ នៅសាលមហោស្រពកោះពេជ្រ

-អញ្ជើញព្រលែងកូនត្រីក្នុងអូរធម្មជាតិ ស្ថិតនៅភូមិដំណាក់កកោះ ឃុំសំរោងលើ ស្រុកអង្គស្នួល ខេត្តកណ្តាល

-អញ្ជើញទៅសួរសុខទុក្ខឯកឧត្តមព្រឹទ្ធាចារ្យ **ប៊ូ ថង** អតីតប្រធានគណៈកម្មការ មហាផ្ទៃ ការពារជាតិ ទំនាក់ទំនងព្រឹទ្ធសភា រដ្ឋសភា និងអធិការកិច្ចនៃព្រឹទ្ធសភា នៅ ភូមិគ្រឹះក្នុងសង្កាត់បឹងកេងកង១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ

-អញ្ជើញជាអធិបតីប្រទានភ្លើងបូជាសពឯកឧត្តម **ឡាយ អ៊ីពិសិទ្ធ** សមាជិក ព្រឹទ្ធសភា មណ្ឌលភូមិភាគទី៧ និងលោកជំទាវ **ស៊ីង ស៊ីយុត** សមាជិកព្រឹទ្ធសភា និង ជាលេខាធិការគណៈកម្មការ អប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ វិចិត្រសិល្បៈ និងទេសចរណ៍ នៅទីវាលមេរុមុខវត្តបទុមវតី សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានី-ភ្នំពេញ

-អញ្ជើញជាអធិបតីក្នុងពិធីបញ្ចុះសព ឯកឧត្តមនាយឧត្តមសេនីយ៍ **ស៊ើយ កែវ** សមាជិកព្រឹទ្ធសភា នៅវត្តរតនារាម ហៅវត្តអូរចេង ភូមិតាអង ស្រុកកូនមុំ ខេត្តរតនគិរី

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២១ច្បាប់ និង ជូនជ្រាបជាព័ត៌មានចំនួន៤៨ច្បាប់។

**១.២-ឯកឧត្តម ស៊ុំ កា អនុប្រធានទី១ ព្រឹទ្ធសភា បាន :**

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៤ចំនួន ០១លើក និងកិច្ចប្រជុំព្រឹទ្ធសភាជាវិសាមញ្ញចំនួន០១លើក

-អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបូជាសពឯកឧត្តម **ឡាយ អ៊ីពិសិទ្ធ** សមាជិក ព្រឹទ្ធសភា មណ្ឌលភូមិភាគទី៧ និងលោកជំទាវ **ស៊ីង ស៊ីយុត** សមាជិកព្រឹទ្ធសភា និងជា លេខាធិការគណៈកម្មការ អប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ វិចិត្រសិល្បៈ និង

ទេសចរណ៍ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៅទីវាលមេរុមុខវត្តបទុមវតី សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

-អញ្ជើញទៅសួរសុខទុក្ខឯកឧត្តមព្រឹទ្ធាចារ្យ **ប៊ូ ថង** អតីតប្រធានគណៈកម្មការមហាផ្ទៃ ការពារជាតិ ទំនាក់ទំនងព្រឹទ្ធសភា រដ្ឋសភា និងអធិការកិច្ចនៃព្រឹទ្ធសភា សម្រាកព្យាបាលនៅមន្ទីរពេទ្យកាល់ម៉ែត្រ រាជធានីភ្នំពេញ

-ពិនិត្យ ផ្តល់យោបល់ ចុះហត្ថលេខាលើឯកសារផ្សេងៗ និងជូនជ្រាបជាព័ត៌មានចំនួន៣២ច្បាប់ៗ

**១.៣-ឯកឧត្តម ខេព ងន អនុប្រធានទី២ ព្រឹទ្ធសភា បាន** :

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០១លើក និងកិច្ចប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤ចំនួន០១លើក

-អញ្ជើញចូលរួមប្រជុំការងារផ្សេងៗ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា

-អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តមកពីប្រទេសបារាំងទៅពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ នៅឃុំភ្នំបាត ស្រុកពញាឮ ខេត្តកណ្តាល

-អញ្ជើញជួបសំណេះសំណាល និងសួរសុខទុក្ខសមាជិក សមាជិកា ក្រុមប្រឹក្សាឃុំ សង្កាត់ ប្រធានប៉ុស្តិ៍រដ្ឋបាល និងស្មៀនឃុំ សង្កាត់ ក្នុងស្រុកលើកដែក ស្រុកគៀនស្វាយ ស្រុកកោះធំ ស្រុកស្អាង ស្រុកខ្សាច់កណ្តាល ស្រុកល្វាឯម និងក្រុងតាខ្មៅ ខេត្តកណ្តាល សរុបចំនួន៧៣៦នាក់

-អញ្ជើញទៅសួរសុខទុក្ខឯកឧត្តមព្រឹទ្ធាចារ្យ **ប៊ូ ថង** អតីតប្រធានគណៈកម្មការមហាផ្ទៃ ការពារជាតិ ទំនាក់ទំនងព្រឹទ្ធសភា រដ្ឋសភា និងអធិការកិច្ចនៃព្រឹទ្ធសភា សម្រាកព្យាបាលនៅមន្ទីរពេទ្យកាល់ម៉ែត្រ រាជធានីភ្នំពេញ

-អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបូជាសពឯកឧត្តម **ឡាយ អ៊ីពិសិទ្ធ** សមាជិកព្រឹទ្ធសភា មណ្ឌលភូមិភាគទី៧ និងលោកជំទាវ **ស៊ីង ស៊ីយុត** សមាជិកព្រឹទ្ធសភា និងជាលេខាធិការគណៈកម្មការ អប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ វិចិត្រសិល្បៈ និងទេសចរណ៍ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៅទីវាលមេរុមុខវត្តបទុមវតី សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

-អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា ដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធសពឯកឧត្តមនាយឧត្តមសេនីយ៍ **ស៊ើយ កែវ** សមាជិកព្រឹទ្ធសភា និងពិធីបញ្ចុះសព ក្រោម

អធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៅវត្តរតនារាម ហៅវត្តអូរចេង ភូមិតាអង ស្រុកកូនមុំ ខេត្តរតនគិរី

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៦៥ច្បាប់ និងជូនជ្រាបជាព័ត៌មានចំនួន២០ច្បាប់។

**២-សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា**

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា បានបើកកិច្ចប្រជុំចំនួន០១លើក ដែលមានរបៀបវារៈដូចខាងក្រោម:

១-ពិនិត្យ និងសម្រេចលើសំណើរបស់គណបក្សប្រជាជនកម្ពុជាលេខ:០៣២/១៩ លគ.គក ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ និងលេខ: ០៣៤/១៩ លគ.គក ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ២០១៩

២-ពិនិត្យ និងសម្រេចលើបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងជាសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

៣-ពិនិត្យសំណើរបស់សមាជិកព្រឹទ្ធសភា ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ ស្នើសុំកោះប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ

៤-កំណត់របៀបវារៈ កាលបរិច្ឆេទ និងសមាភាពលេខាធិការអង្គប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤។

**៣-កិច្ចប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ**

ព្រឹទ្ធសភាបានបើកសម័យប្រជុំវិសាមញ្ញចំនួន០១លើកដើម្បី៖

១-ប្រកាសទទួលស្គាល់សមាជិកព្រឹទ្ធសភាថ្មី នីតិកាលទី៤

២-ការបោះឆ្នោតជ្រើសតាំងសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ចំនួន០១រូប សម្រាប់ជំនួសសមាជិកដែលត្រូវបញ្ចប់អាណត្តិ។

**៤-គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា**

ក្នុងខែសីហានេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារតាមតួនាទីភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនយ៉ាងសកម្ម ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម:

**៤.១-មុខងារតាមដានការអនុវត្តច្បាប់**

-អញ្ជើញចុះសិក្សាឈ្វេងយល់អំពី ប្រសិទ្ធភាពក្នុងការអនុវត្តច្បាប់ និងលិខិត-បទដ្ឋានគតិយុត្តដែលពាក់ព័ន្ធលើកិច្ចប្រតិបត្តិការរបស់អភិបាលនៃគណៈអភិបាលខេត្ត

កងកម្លាំងប្រដាប់អាវុធទាំង៣ប្រភេទរបស់ខេត្ត មន្ទីរទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច និងមន្ទីរមុខងារសាធារណៈ ព្រមទាំងបញ្ហាប្រឈមនានា នៅខេត្តកំពត

-អញ្ជើញចុះសិក្សាឈ្វេងយល់អំពី ការវិវត្តរីកចម្រើន និងបញ្ហាប្រឈមរបស់ខេត្ត និងមន្ទីរពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ច នៅខេត្តកំពង់ធំ

-អញ្ជើញចុះសិក្សាឈ្វេងយល់អំពី ការអនុវត្តច្បាប់ស្តីពី ការប្រឆាំងអំពើពុករលួយ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងការអភិវឌ្ឍមូលដ្ឋាន នៅខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ

-អញ្ជើញចុះសិក្សាស្រាវជ្រាវអំពី ដំណើរការរោងចក្រផលិតថាមពលអគ្គិសនី ដើរដោយពន្លឺព្រះអាទិត្យ នៅត្មាតពង ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ

-អញ្ជើញចុះសិក្សាឈ្វេងយល់អំពី ការអនុវត្តច្បាប់អន្តោប្រវេសន៍ និងការផ្សព្វ-ផ្សាយព័ត៌មាន នៅខេត្តកំពង់ធំ ខេត្តឧត្តរមានជ័យ និងខេត្តបន្ទាយមានជ័យ។

### ៤.២-មុខងារតំណាង

-បានទទួលពាក្យបណ្តឹងចំនួន០៨ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងចំនួន ០៤ករណី ធ្វើលិខិតអន្តរាគមន៍ទៅក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីដោះស្រាយចំនួន០៤ ករណី ទទួលលិខិតឆ្លើយតបអំពីការដោះស្រាយពាក្យបណ្តឹងរបស់ក្រសួង ស្ថាប័នពាក់-ព័ន្ធចំនួន០១ករណី និងឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន០៤ករណី កំពុងពិនិត្យសិក្សា ចំនួន០៦ករណី ព្រមទាំងទទួលឯកសារពាក្យបណ្តឹងដែលក្រសួង ស្ថាប័នពាក់ព័ន្ធចម្លង ជូនគណៈកម្មការដើម្បីជូនជ្រាបចំនួន០៧ករណី

-អញ្ជើញចូលរួមក្នុងវេទិកាអន្តរសាសនាថ្នាក់ជាតិ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញ ដូរមនុស្សលើកទី៣

-អញ្ជើញចូលរួមប្រជុំត្រៀមលក្ខណៈដើម្បីចូលរួមមហាសន្និបាតអាយប៉ា (AIPA) លើកទី៤០

-អញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាអំពី គម្រោងថវិកាឆ្នាំ២០២០របស់ព្រឹទ្ធសភា ជាមួយនឹងក្រុមការងារថ្នាក់ដឹកនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-អញ្ជើញចូលរួមប្រជុំពិភាក្សាការងារជាមួយថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និង កីឡា ដើម្បីឈ្វេងយល់អំពី ការរីកចម្រើនថ្មីៗក្នុងវិស័យអប់រំ បញ្ហាប្រឈម វិធានការ និងចក្ខុវិស័យទៅមុខរបស់ក្រសួង

*-អញ្ជើញជួបពិភាក្សា និងស្តាប់បទបង្ហាញរបស់តំណាងអង្គការចលនាដើម្បីសុខភាពកម្ពុជា*(CMH) *ពីលទ្ធផលនៃការអង្កេតអំពីការអនុលោមតាមច្បាប់ស្តីពី ការត្រួតពិនិត្យផលិតផលថ្នាំជក់*

*-អញ្ជើញជួបពិភាក្សាស្វែងយល់អំពីស្ថានភាព វិធានការបង្ការ ទប់ស្កាត់ និងព្យាបាលជំងឺរបេងនៅកម្ពុជា ជាមួយអង្គការខាណា*(KHANA)

*សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះទៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងចំនួន៩២លើក ដើម្បីជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព សិក្សាឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោល-នយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន១២៩លើក ។*

**៥- កិច្ចសហប្រតិបត្តិការអន្តរជាតិ**

*-ឯកឧត្តម **យ៉ង់ សែម** អញ្ជើញចូលរួមមហាសន្និបាតអាយប៉ា* (AIPA) *លើកទី៤០ នៅទីក្រុងបាងកក នៃព្រះរាជាណាចក្រថៃឡង់ដ៍*

*-ឯកឧត្តម **សុខ ឥសាន** ឯកឧត្តម **ជឹម លាវ** និងឯកឧត្តម **ញ៉ែម សាម៉ន** អញ្ជើញចូលរួមសន្និសីទលើកទី៧ នៃគណៈកម្មការបរទេសនៃរដ្ឋសភាប្រទេសទាំងបី កម្ពុជា-ឡាវ-វៀតណាម* (CLV) *នៅទីក្រុងហាណូយ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម*

*-ឯកឧត្តម **ទេព យុទ្ធី** អញ្ជើញចូលរួមវេទិកាសភាអាស៊ី-ប៉ាស៊ីហ្វិកលើកទី៥ស្តីពីការលើកកម្ពស់តួនាទីសមាជិកសភា ក្នុងការដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ និងសុខភាព នៅទីក្រុងណាឌី* (Nadi) *នៃប្រទេសហ្វីជី*(Fiji)

*-លោកជំទាវ **ទី បូរ៉ាស៊ី** អនុញ្ញាតឱ្យលោកបណ្ឌិត* **Amaury Peeters** *នាយកកម្មវិធី* Louvain Coopération *នៃព្រះរាជាណាចក្របែលហ្ស៊ិក ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ*

-ឯកឧត្តម **គង់ សារាជ** ឯកឧត្តម **ម៉ុម ជីមហ៊ុយ** និងឯកឧត្តម **ម៉ាន់ ឈឿន** អញ្ជើញជួបពិភាក្សាការងារជាមួយឯកឧត្តម **Wang Wentian** ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋ-ប្រជាមានិតចិនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

-ឯកឧត្តម **ម៉ុង ឫទ្ធី** អនុញ្ញាតឱ្យលោក **Yuji Wahei** ព្រមទាំងសហការី ចូលជួបពិភាក្សាការងារដើម្បីរកឱកាសបណ្តាក់ទុនវិនិយោគលើដំណាំទំពាំងបាយជូរ ផលិតជាស្រា និងទឹកទំពាំងបាយជូរ ។ ៷

ថ្ងៃ ចន្ទ ១១កើត ខែភទ្របទឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៩

**ជ.ប្រធានព្រឹទ្ធសភា**
**អនុប្រធានទី២**

**ទេព ងន**

ចម្លងជូន:

- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ